# កេសរកូលព្រៃ (អ័រគីដេ) នៅប្រទេសកម្ពុជា

# Wild Orchids of Cambodia




ចងក្រងដោយ

បណ្ឌិត កែវ អូម៉ាលីស្ស Dr. Andre Schuiteman Dr. Marpha Telepova-Texier Mr. Cedric Jancloes

Ms. Chantheanna Jancloes កញ្ញា ណៃ ស៊ីខឿន និងកញ្ញា អាត់ ស្រីណាក់


២០២១



កេសរកូលព្រៃ (អ័រគីដេ) ចារឹកនៅប្រាសាទ អង្គរវត្ត

# អារម្ភកថា

ប្រទេសកម្ពុជាសំបូរទៅដោយធនធានធម្មជាតិព្រៃឈើ និងសត្វព្រៃ រួមទាំងរុក្ខជាតិគ្រប់ប្រភេទ។ សម្បត្តិធម្មជាតិទាំងនេះ មិនត្រឹមតែបានផ្តល់នូវសោភ័ណភាពស្រស់ត្រកាលប៉ុណ្ណោះទេ ថែមទាំងបានទ្រទ្រង់ដ៏សំខាន់សម្រាប់សេដ្ឋកិច្ចសង្គម និងបរិស្ថាន។ ក្នុងកំឡុងបួនទស្សវត្សកន្លងមកនេះ ក្រោមការដឹកនាំ ដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រមុតស្រួចក្នុងការការពារ ថែរក្សាធនធានព្រៃឈើ រួមទាំងបានធ្វើឲ្យការស្រាវជ្រាវវិទ្យាសាស្ត្ររុក្ខជាតិ កាន់តែមានភាពប្រសើរឡើង និងរីកចម្រើនទៅមុខ។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននឹងកំពុងខិតខំពង្រីកការស្រាវជ្រាវរុក្ខជាតិព្រៃ រួមទាំងកេសរកូលព្រៃ (អ័រគីដេ) និងធ្វើការថែរក្សាសំណាករស់ និងសំណាកស្ងួត ដែលជាធនធានដ៏មានតម្លៃ។

សៀវភៅកេសរកូលព្រៃ គឺជាស្នាដៃបោះពុម្ពលើកទី១ សម្រាប់ប្រទេសកម្ពុជា ហើយវាបានគ្របដណ្តប់ទៅលើប្រភេទកេសរកូល ២០២ ប្រភេទក្នុងចំណោមកេសរកូលជាង ៥០០ ប្រភេទដែលមាននៅក្នុងប្រទេសកម្ពុជា។

សៀវភៅនេះនឹងរួមវិភាគទានដ៏សំខាន់មួយសម្រាប់សិស្សនិស្សិត មន្ត្រីរាជការ និងដៃគូអភិវឌ្ឍន៍នានា ប្រើប្រាស់ជាមគ្គុទេសក៍ក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍។ លើសពីនេះទៅទៀត សៀវភៅនេះនឹងបានលើកស្ទួយមុខមាត់របស់ប្រទេសកម្ពុជាលើការថែរក្សា ស្រាវជ្រាវ និងយកចិត្តទុកដាក់ខ្ពស់ទៅលើប្រភេទកេសរកូលព្រៃទាំងនេះ។

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**វេង សាខុន**


© A. Sreynak, FA 2018



# ការថ្លែងអំណរគុណ

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានជួយ គាំទ្រលើការស្រាវជ្រាវកន្លងមក និងក្រសួងបរិស្ថាន ដែល បានសហការ និងអនុញ្ញាតឲ្យមានការសិក្សាទៅតាមតំបន់ ការពារ។ សូមថ្លែងអំណរគុណចំពោះអ្នកបច្ចេកទេសដែល បានសិក្សាស្រាវជ្រាវកេសរកូលកន្លងមក និងអ្នកស្ម័គ្រចិត្ត ជាច្រើនទៀត ដែលបានចូលរួមរៀបចំចងក្រងសៀវភៅ កេសរកូលព្រៃ នៅប្រទេសកម្ពុជានេះ។ សូមថ្លែងអំណរគុណ បណ្ឌិត ហ៊ុល សុវណ្ណម៉ូលី បណ្ឌិត ផាត ផាន់ណា និង លោក ផាន វុទ្ធី ដែលបានចូលរួមត្រួតពិនិត្យ និងយោបល់ កែសម្រួលសៀវភៅកេសរកូលនេះ។ យើងខ្ញុំសូមថ្លែងអំណរ គុណសម្រាប់ការចូលរួមផ្តល់ជារូបថត និងចែករំលែកព័ត៌មាន របស់លោក សារ ធីម លោក សុង ដេត លោក លី វិបុត្រ លោក Jeremy Holden លោក J.P. Delpal លោក Olga Averyanov និងលោក Rob Overtoom។

សូមថ្លែងអំណរគុណ ចំពោះប្រជាពលរដ្ឋដែលបាន ផ្តល់ឈ្មោះតាមតំបន់របស់កេសរកូលនីមួយៗ និងអ្នកដែល បានជួយជ្រោមជ្រែងលើការងារនេះ និងជាពិសេសសូមថ្លែង អំណរគុណចំពោះ Korea-Mekong Forest Cooperation Center ដែលបានឧបត្ថម្ភថវិកាក្នុងការបោះពុម្ពសៀវភៅ នេះឡើង។

# សារតារ

រដ្ឋបាលព្រៃឈើ បានយកចិត្តទុកដាក់លើការស្រាវជ្រាវវិទ្យាសាស្ត្រទៅលើប្រភេទរុក្ខជាតិ រួមទាំងកេសរកូលព្រៃ អស់រយៈពេលជាច្រើនទសវត្សមកហើយ ដោយមានការសហការជាមួយដៃគូអភិវឌ្ឍនានា។ ការសិក្សាស៊ីជម្រៅលើកេសរកូលព្រៃបានជំរុញកាន់តែខ្លាំងឡើង បន្ទាប់ពីមានកិច្ចសហការជាមួយសួនរុក្ខសាស្ត្រ (KEW) ដែលជាអង្គភាពមួយមានចំណេះដឹងខ្ពស់លើការស្រាវជ្រាវរុក្ខជាតិកេសរកូលនៅក្នុងពិភពលោក។ ទន្ទឹមនឹងនេះកិច្ចសហការល្អជាមួយលោក Cedric Jancloes រួមទាំងអ្នកវិទ្យាសាស្ត្រជាច្រើនក៏បានជួយពន្លឿនការស្រាវជ្រាវនេះឲ្យកាន់តែមានប្រសិទ្ធភាព។ ទោះបីជាថវិកានៅមានកម្រិត រដ្ឋបាលព្រៃឈើបានខិតខំរៀបចំសួនអភិរក្ស ថែរក្សាសំណាកកេសរកូលព្រៃចាប់តាំងពីដើមឆ្នាំ២០១៦ រហូតមកដល់ឆ្នាំ២០២០ ទីកន្លែងនេះបានរក្សាសំណាកកេសរកូលព្រៃជាច្រើនប្រភេទ និងជាទីកន្លែងសម្រាប់សិស្ស និស្សិតទូទាំងប្រទេសមកធ្វើការសិក្សាស្រាវជ្រាវ។

បច្ចុប្បន្ននេះ យើងបានស្រាវជ្រាវរកឃើញកេសរកូលព្រៃជាង ៥០០ប្រភេទ ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ហើយការសិក្សាស្រាវជ្រាវនេះនៅតែបន្តស្វែងរកប្រភេទថ្មីៗបន្ថែមទៀត។

# ប្រវត្តិធម្មជាតិ

រុក្ខជាតិអង់ស្យូស្ពែម (Angiospermophyta) ជារុក្ខជាតិ ដែលបន្តពូជបង្កើតជាគ្រាប់នៅក្នុងផ្លែ ដែលមានប្រមាណជាង ១៤០ លានឆ្នាំមុន។ ក្រុមនេះត្រូវបានគេរកឃើញថាជារុក្ខជាតិផ្កា ដែលក្រុមរបស់វាបានរីករាលដាលធំជាងគេបំផុតនៅលើភពផែនដី ដែលមានចំនួនជិតដល់ ៤០០,០០០ប្រភេទ។ លក្ខណៈពិសេសនៃរុក្ខជាតិមានផ្កាគឺការធ្វើដំណើរលំអង ដែលជាធម្មតាវាកើតឡើងតាមរយៈសកម្មភាពរបស់សត្វល្អិត។ ព័ត៌មានសេនេទិចបានបង្ហាញថាកេសរកូលអាចកើតឡើងតាំងពី ១០២ ទៅ១២០ លានឆ្នាំមុនមកម្ល៉េះ។ កេសរកូល (អ័រគីដេ) មានភាពល្បីល្បាញជាពិសេស ដោយសារតែរាប់លានឆ្នាំមុនវាមានការវិវត្តនូវលក្ខណៈពិសេសៗជាច្រើន ដើម្បីទាក់ទាញភ្នាក់ងារនាំលំអង (pollinators) និងបង្កើនឱកាសនៃការរស់លូតលាស់ និងការបន្តពូជ។ កេសរកូលមានប្រមាណ ២៧,០០០ ប្រភេទដែលត្រូវបានគេទទួលស្គាល់ និងត្រូវចាត់បញ្ចូលក្នុង ៧៥៨ ពួក និងដែលស្ថិតក្នុងអំបូរកេសរកូល (Orchidaceae) ជាអំបូរដ៏ធំបំផុតក្នុងពិភពរុក្ខជាតិ។ កេសរកូល ជាប្រភេទរុក្ខជាតិមានសរសៃនាំ និងជារុក្ខជាតិអង់ស្យូស្ពែមដែលមានផ្កា មានគ្រាប់ហើយគ្រាប់ស្ថិតនៅក្នុងផ្លែ។ វាក៏ជារុក្ខជាតិម៉ូណូកូទីលេដុង (Monocots) ដែលមានកូទីលេដុងតែមួយ។ ហើយវាអាចជាពពួកអេពីហ្វីត (Epiphyte) ដែលជារុក្ខជាតិដុះលើរុក្ខជាតិមួយផ្សេងទៀត ហើយវាអាចជាលីតូហ្វីត (Lithophyte) ដែលជារុក្ខជាតិដុះលើថ្ម និងអាចជារុក្ខជាតិដុះលើដី (terrestrial) ផងដែរ។

ជាទូទៅលក្ខណៈលូតលាស់របស់កេសរកូល ជាពពួកស៊ីម៉ូប៉ូឌីយ៉ាល់ (Sympodial) ឬម៉ូណូប៉ូឌីយ៉ាល់ (Monopodial)។

# សញ្ញាសម្គាល់

- លក្ខណៈរូបសាស្ត្រ
- ជម្រក
- រយៈកម្ពស់
- រដូវចេញផ្កា
- ទំហំដើម
- ការពិពណ៌នា
- ក្លិន
- ឈ្មោះអ្នករកឃើញដំបូងមុនឆ្នាំ១៩៧៥។

# មាតិកា ទំព័រ

អារម្ភកថា
ការថ្លែងអំណរគុណ ..... ១
សារតារ ..... ២
ប្រវត្តិធម្មជាតិ ..... ៣
សញ្ញាសម្គាល់ ..... ៤
ពាក្យគន្លឹះ ..... ៦
វដ្តជីវិត ..... ៨
ផ្កា ..... ៩
ព័ត៌មានកេសរកូល ..... ១៣
រដូវចេញផ្កា ..... ២១៥
ឯកសារយោង ..... ២២១
ច្បាប់ និងអនុសញ្ញា (CITES) ..... ២២៤

# ពាក្យគន្លឹះ

កេសរកូល គឺជាប្រភេទរុក្ខជាតិអង់ស្យូស្ពែម ដែលមានផ្កា និងគ្រាប់នៅក្នុងផ្លែ និងជារុក្ខជាតិម៉ូណូកូទីលេដូន ដែលមានកូទីលេដុងតែមួយ។

- អេពីហ្វីត (Epiphyte) គឺជាប្រភេទរុក្ខជាតិ ដែលដុះនៅលើរុក្ខជាតិមួយផ្សេងទៀត
- លីតូហ្វីត (Lithophyte) គឺជាប្រភេទរុក្ខជាតិ ដែលអាចសម្របខ្លួនដោយការបន្សាំដុះលើថ្ម
- ធ័ររ៉េសត្រេល (Terrestrial) គឺជារុក្ខជាតិ ដែលដុះលើដី
- ម៉ូណូប៉ូឌីយ៉ាល់ (Monopodial) គឺជាប្រភេទរុក្ខជាតិ ដែលមានដើមតែមួយ និងលូតលាស់ទៅលើ
- ស៊ាំប៉ូឌីយ៉ាល់ (Sympodial) គឺជាប្រភេទរុក្ខជាតិ ដែលលូតលាស់ទៅផ្នែកចំហៀងដើម ។




ម៉ូណូប៉ូឌីយ៉ាល់ (Monopodial)




ស៊ុំប៉ូឌីយ៉ាល់ (Sympodial)




# វដ្តជីវិត




បកប្រែដោយ កញ្ញា ណៃ ស៊ីខឿន

# ផ្កា

ផ្កាកេសរកូល សម្គាល់ដោយមានត្របកផ្កាចំនួន ៣ ដែលជាទូទៅមានទំហំ និងរូបរាងប្រហាក់ប្រហែលគ្នាមានស្រទាប់ចំនួន២ ហើយមានស្រទាប់ផ្កានៅចំកណ្តាល១ (ហៅថាអណ្តាតផ្កា) ដែលមានរាងខុសពីគេ។ សំណុំផ្កាអាចបង្កើតបានជានព្វន្ត ៣+២+១ តំណភ្ជាប់គ្នារវាងកេសរញី និងកេសរឈ្មោលដែលរលាយចូលគ្នាជាសរីរាង្គតែមួយ ហៅថាកូឡូន (column) ។ នៅក្នុងបរិវេណដែលមាននៅលើជួរឈរ និងជួរដេកជួនកាលវាអាចបង្កើតទឹកដម និងក្លិនដែលធ្វើឲ្យទាក់ទាញ។




© N. Sikhoeun, FA 2019

# កេសរកូលព្រៃ (អ័រគីដេ)
# នៅប្រទេសកម្ពុជា




© N. Sikhoeun, FA 2018

# A កេសរកូល ខ្លាញ់ក្តាមអណ្តាតស

## **Acampe carinata**

- ពពួកអេពីហ្វីត និងម៉ូណូប៉ូឌីយ៉ាល់
- ដុះតាមដីទំនាប និងព្រៃភ្នំ
- ០-៤០០ ម
- ខែកុម្ភៈ
- តូច-ធំ
- ស្លឹកមានទំហំ < ២,៥ស.ម កញ្ចុំផ្កាមានប្រវែង ២-៥ស.ម ហើយផ្កានីមួយៗមានវិជ្ជមាត្រ ១,៥ ស.ម
- **(Griff.) Panigrahi 1985 Equam**

ប្រភេទកេសរកូលដែលមាននៅប្រទេសកម្ពុជា
(A. hulae Telepova - see Herbarium section)។

